ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០១៥......សហវ.ពន្ធ

# សេចក្តីណែនាំ
## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤៧ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចតទៅ÷

### ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវចាប់អនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតក្នុងខែមករា ឆ្នាំ២០១៧ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃ ទី២០ នៃ ខែកុម្ភៈ ឆ្នាំ២០១៧។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ ០០០ ០០០ ៛ | 0% |
| ពី | ១ ០០០ ០០១ ៛ | ដល់ | ១ ៥០០ ០០០ ៛ | ៥% |
| ពី | ១ ៥០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១0% |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២0% |

### ២. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ ដើម្បីសម្រួលជីវភាពរស់នៅរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ រាជរដ្ឋាភិបាលក៏បានសម្រេចធ្វើការដំឡើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗពី ៧៥ ០០០ រៀល ដល់ ១៥០ ០០០ រៀល ក្នុងមួយខែ (កើនឡើងពីរដង)។ ការដំឡើងកម្រិតកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែតិចដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សលើសពី ១ ០០០ ០០០ រៀល អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

### ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

ក- យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះ ការបំពេញសកម្មភាពបំរើការងារ។

ខ- ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិត រោងចក្រ សហគ្រាស ទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០០១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

គ- ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សសរុប ក្រៅពីប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ដូចមានក្នុងចំណុច ខ ខាងលើ ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធ សម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ០០០ ០០០ រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

ឃ- តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រា | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី ០៛ ដល់ ១ ០០០ ០០០៛ | ០% | ០៛ |
| ពី ១ ០០០ ០០១៛ ដល់ ១ ៥០០ ០០០៛ | ៥% | ៥០ ០០០៛ |
| ពី ១ ៥០០ ០០១៛ ដល់ ៨ ៥០០ ០០០៛ | ១០% | ១២៥ ០០០៛ |
| ពី ៨ ៥០០ ០០១៛ ដល់ ១២ ៥០០ ០០០៛ | ១៥% | ៥៥០ ០០០៛ |
| លើសពី ១២ ៥០០ ០០០៛ | ២០% | ១ ១៧៥ ០០០៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស(ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ(លបព)

**ឧទាហរណ៍ទី១÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ២ ០០០ ០០០ រៀល

ក. ករណីនៅលីវ

មពបវ = ២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១០%

លបព = ១២៥ ០០០៛

ពបវ = (២ ០០០ ០០០៛ x ១០%) - ១២៥ ០០០៛ = ៧៥ ០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពប‌រ = ២ ០០០ ០០០៛ - ៦០០ ០០០៛ = ១ ៤០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ៥%

លបព = ៥០ ០០០៛

ពប‌រ = (១ ៤០០ ០០០៛ x ៥%) - ៥០ ០០០៛ = **២០ ០០០៛**

**គ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៦ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៧ = ១ ០៥០ ០០០៛

មពប‌រ = ២ ០០០ ០០០៛ - ១ ០៥០ ០០០៛ = ៩៥០ ០០០៛ ជាប់ពន្ធក្នុងអត្រា ០%

ពប‌រ = 0៛

**ឧទាហរណ៍ទី២÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ១២ ៦០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពប‌រ = ១២ ៦០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ២០%

លបព = ១ ១៧៥ ០០០៛

ពប‌រ = (១២ ៦០០ ០០០៛ x ២០%) - ១ ១៧៥ ០០០៛ = **១ ៣៤៥ ០០០៛**

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛X ៤ = ៦០០ ០០០៛

មពប‌រ = ១២ ៦០០ ០០០៛ - ៦០០ ០០០៛ = ១២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១៥%

លបព = ៥៥០ ០០០៛

ពប‌រ = (១២ ០០០ ០០០៛ x ១៥%) - ៥៥០ ០០០៛ = **១ ២៥០ ០០០៛**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ